ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. 148 MOC / M 2005

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការបង្កើតគណៈកម្មការសំរាប់រៀបចំគំរោងគាំទ្រលើ វិស័យវាយនភ័ណ្ឌនៅក្នុងបរិបទនៃការបាត់បង់ប្រពន្ធ័អនុគ្រោះកូតានៅកម្ពុជា

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦ /១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតំរូវការចាំបាច់

## <u>សំរេច</u>

**ប្រការ ១ :** បង្កើតគណៈកម្មការសំរាប់រៀបចំគំរោងគាំទ្រលើវិស័យវាយនភ័ណ្ឌ នៅក្នុងបរិបទនៃការបាត់បង់ប្រពន្ធ័អនុគ្រោះកូតា នៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជានាយកគំរោង និងជា | ប្រធាន |
| ២-ឯកឧត្តម **ឈួន ដារ៉ា** | អគ្គនាយកបច្ចេកទេសក្រសួងពាណិជ្ជកម្ម | ជាអ្នកសំរបសំរួល និងជា | អនុប្រធាន |
| ៣-លោក **ជួន ចន** | ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៤-លោក **មាន សុភា** | ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៥-លោក **ស៊ាង ថៃ** | ប្រធាននាយកដ្ឋានអាស៊ាននិងអង្គការអន្តរជាតិ | ក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៦-លោកស្រី **ម៉ា ចាន់នី** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ | ក្រសួងកិច្ចការនារី | ជាសមាជិក |
| ៧-លោក **សៀង ឈុនឡុី** | នាយករងទីមួយ ទីចាត់ការគយ និងរដ្ឋាករ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

FTD:2005-05-04/Committee for Textile Support/NC/LC 5/5/2005

Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
URL : http://www.moc.gov.kh E-Mail : moccabdir@yahoo.com
Senior Minister's Cabinet Mobile Phones: (855-12) 933 323 / 881 223 Facsimile: (855-23) 426 396 / 213 288 / 991 708

៨-លោក **អ៊ី សីហា** នាយករងទីមួយ នៃនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៩-លោក **ចន្ទមុនីសត្ថាមុន** អនុប្រធាននាយកដ្ឋាន វិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

១០-លោក **គួយ ទេពជារាមុន** អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ជាសមាជិក

១១- លោក **វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ជាសមាជិក

១២-លោក **ខិន លូ** អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ជាសមាជិក

១៣-លោកស្រី **កែវ មុន្នីតា** ប្រធានការិយាល័យទាក់ទងបរទេស ក្រសួងពាណិជ្ជកម្ម ជាលេខាធិការ

**ប្រការ២:** គណៈកម្មការមានភារកិច្ចដូចតទៅ :

-ជ្រើសរើសជំនួយការបច្ចេកទេសតាមរយៈការដេញថ្លៃ ដោយមានការឯកភាពពី **AFD** ។

-តាមដាននិងគាំទ្រទិសការអនុវត្តន៍គំរោង ។

-ផ្ទេរសិទ្ធិអោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ជាអ្នកអនុវត្តការងារ ។

-ធ្វើជាអ្នកសំរបសំរួលគំរោង រវាងរាជរដ្ឋាភិបាល **-AFD-GMAC** និង **ILO** ។

-រាយការណ៍ជូនឯកឧត្តមទេសរដ្ឋមន្ត្រីអោយបានទៀងទាត់ពីការវិវត្តន៍នៃការអនុវត្តន៍គំរោងគាំទ្រលើវិស័យវាយនភ័ណ្ឌនៅក្នុង បរិបទនៃការបាត់បង់ប្រព័ន្ធអនុគ្រោះកូតានៅកម្ពុជា និងស្នើសុំមតិយោបល់ក្នុងករណី ចាំបាច់ ។

**ប្រការ៣** :គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រាក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេលដំណើរការ ។

**ប្រការ៤** :សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៥:** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស នាយិកាខុទ្ទកាល័យ និងសាមីខ្លួនត្រូវអនុវត្ត សេចក្តីប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន:</u>**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ណាំហុង**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងកិច្ចការនារី

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ដូចប្រការ ៥

-រាជកិច្ច ✓

-ឯកសារ-កាលប្បវត្តិ

FTD/2005-05-04/Committee for Textile Surport/NC/LC 5/5/2005